**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ..១២២..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងគ្រឿងសម្អាង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខជស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០០/០០១ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាកពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ខែសីហាឆ្នាំ២០០៨

# សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅ គ្រប់គ្រងផលិតផលគ្រឿងសម្អាងគ្រប់ប្រភេទ ដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណង ការពារ ទប់ស្កាត់ការផលិត ការចរាចរ ការនាំចូលគ្រឿងសម្អាងក្លែងក្លាយ គ្រឿងសម្អាងខូចគុណភាព គ្រឿងសម្អាងខុសច្បាប់ ដើម្បីធានាគុណភាពនិងសុវត្ថិភាព ដល់អ្នកប្រើប្រាស់ និងសម្រួលការធ្វើពាណិជ្ជកម្មគ្រឿងសម្អាង ។

**មាត្រា ៣.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ ÷

គ្រឿងសម្អាងសំដៅដល់ផលិតផល ដែលផ្សំឡើងដោយសារធាតុគីមី ជីវៈផលិតផលរុក្ខជាតិឬសិលាជាតិ សម្រាប់ប្រើលើបណ្តាផ្នែកខាងក្រៅនៃខ្លួនមនុស្ស (ស្បែក សក់ ក្រចក បបូរមាត់ និងផ្នែកខាងក្រៅអវយវៈភេទ) ឬប្រើលើធ្មេញ និងជាលិកាទន់នៃក្រអូមមាត់ ក្នុងគោលបំណង សំអាត ការពារ ថែរក្សា ធ្វើឱ្យក្រអូប ផ្លាស់ប្តូររូបភាព ខាងក្រៅ និងបំបាត់ក្លិនខ្លួន ។

គ្រឿងសម្អាងក្លែងក្លាយ ឬក្លែងបន្លំ សំដៅដល់ ផលិតផលដែលមានសារធាតុផ្សំមិនគ្រប់ចំនួន ខុសកម្រិត ឬមិនត្រឹមត្រូវតាមសមាសធាតុផ្សំ ដែលផលិតករបានរៀបរាប់ ក្នុងឯកសារទុកនៅក្រុមហ៊ុន ឬរូបមន្ត ដែលបានកំណត់លើស្លាកសញ្ញាផលិតផល ដែលផលិតឬវេចខ្ចប់ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលគ្មានអាជ្ញាប័ណ្ណ ពីស្ថាប័នមានសមត្ថកិច្ចផលិតផលដែលមានស្លាកសញ្ញា ឬមានការវេចខ្ចប់ របៀបបង្ហាញរចនាបថ អត្តសញ្ញាណស្រដៀងនឹងគ្រឿងសម្អាងមួយផ្សេងទៀត ដែលជាគ្រឿងសម្អាងពិត ។

គ្រឿងសម្អាងខូចគុណភាព សំដៅដល់ផលិតផល ដែលទុកដាក់មិនត្រឹមត្រូវតាមលក្ខខណ្ឌបច្ចេកទេស និងផលិតផលដែលហួសកាលបរិច្ឆេទប្រើប្រាស់ ។

គ្រឿងសម្អាងខុសច្បាប់ សំដៅដល់ផលិតផលដែលគ្មានលេខប្រវេទន៍ ។

អ្នកស្នើសុំប្រវេទន៍ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលខុសត្រូវអំពីគុណភាព និងសុវត្ថិភាពផលិតផលគ្រឿងសម្អាង ដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

ការធ្វើប្រវេទន៍ សំដៅដល់ការបំពេញបែបបទនៃការចុះបញ្ជិកាតាមបែបសាមញ្ញ សម្រាប់ជូនព័ត៌មានអំពីផលិតផល ដល់ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងគ្រឿងសម្អាង ។

## ជំពូកទី ២
## ការធ្វើប្រវេទន៍លើផលិតផលគ្រឿងសម្អាង

**មាត្រា ៤.-**

គ្រឿងសម្អាងដែលនាំចូល ឬផលិត សម្រាប់ធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលេខប្រវេទន៍ ពីក្រសួងសុខាភិបាល ។

គ្រឿងសម្អាងដែលនាំចូលសម្រាប់ការតាំងពិព័រណ៍ ការសិក្សាស្រាវជ្រាវ និងសម្រាប់ជាវត្ថុអនុស្សាវរីយ៍ត្រូវបានលើកលែងការធ្វើប្រវេទន៍ តែត្រូវមានការសុំអនុញ្ញាតពីក្រសួងសុខាភិបាល ។

បែបបទនិងនិតិវិធីនៃការចេញលេខប្រវេទន៍ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

កម្រៃនៃការចេញលេខប្រវេទន៍ ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៥.-**

ក្រសួងសុខាភិបាលមានសិទ្ធិដកហូតលេខប្រវេទន៍ ក្នុងករណីគ្រឿងសម្អាងនោះបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ។

**មាត្រា ៦.-**

ក្នុងករណីមានការត្រួតពិនិត្យ របស់ស្ថាប័នមានសមត្ថកិច្ច គ្រប់គ្រងគ្រឿងសម្អាង អ្នកស្នើសុំប្រវេទន៍ ត្រូវត្រៀមឱ្យមានជាស្រេចនូវឯកសារបច្ចេកទេសនិងបណ្តាឯកសារពាក់ព័ន្ធអំពីសុវត្ថិភាពគ្រឿងសម្អាង ដូចជា ៖

-រូបមន្តរបស់ផលិតផល ដោយបញ្ជាក់អំពីឈ្មោះ និង បរិមាណសារធាតុ ដែលផ្ទុកក្នុងផលិតផលគ្រឿងសម្អាង ។ ដោយឡែកចំពោះគ្រឿងសម្អាង ដែលមានសារធាតុផ្សំជាគ្រឿងក្រអូប ត្រូវបញ្ជាក់ឈ្មោះសារធាតុ លេខកូដ និងឈ្មោះអ្នកផ្គត់ផ្គង់

-របៀបត្រួតពិនិត្យសារធាតុគីមី ដោយភ្ជាប់មកជាមួយ នូវវិញ្ញាបនបត្រត្រួតពិនិត្យគុណភាព

-បណ្តាលក្ខខណ្ឌក្នុងការវិភាគស្រាវជ្រាវរកអតិសុខុមប្រាណ ក្នុងផលិតផលគ្រឿងសម្អាង និងកំណត់ភាពសុទ្ធរបស់សារធាតុគីមី ព្រមទាំងវិធីសាស្ត្រត្រួតពិនិត្យឆ្លើយតបទៅនឹងបណ្តាលក្ខខណ្ឌដែលបានគ្រោងទុក

-យថាប្រភេទរបស់សារធាតុផ្សំគ្រឿងសម្អាង និងផលិតផលសម្រេច

-របៀបផលិតដែលអនុវត្តតាមគោលការណ៍អនុវត្តផលិតកម្មល្អ ក្នុងការផលិតគ្រឿងសម្អាង

-ការវាយតម្លៃលើការត្រួតពិនិត្យ អំពីសុវត្ថិភាពនៃផលិតផលសម្រេច សារធាតុផ្សំរចនាសម្ព័ន្ធគីមី និងកំណត់ផលប៉ះពាល់ លើផ្នែកខាងក្រៅនៃខ្លួនមនុស្ស

-បញ្ជាក់ផលវិបាកបន្ទាប់បន្សំ ចំពោះអ្នកប្រើប្រាស់ក្រោយពីការប្រើផលិតផល

-ត្រូវមានទិន្នន័យគ្រប់គ្រាន់ បញ្ជាក់អំពីប្រសិទ្ធភាពរបស់គ្រឿងសម្អាង ។

ឯកសារបច្ចេកទេសពាក់ព័ន្ធ អំពីសុវត្ថិភាពគ្រឿងសម្អាង ត្រូវសរសេរជា អក្សរខ្មែរ និង អក្សរអង់គ្លេស ឬអក្សរបារាំង ។

**មាត្រា ៧.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលទទួលខុសត្រូវ ក្នុងការធ្វើអាជីវកម្មផលិតផលគ្រឿងសម្អាង លើទីផ្សារ ត្រូវគោរពបែបបទនៃការធ្វើអាជីវកម្ម ដែលកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## ជំពូកទី ៣
## លក្ខខណ្ឌធានាសុវត្ថិភាព

**មាត្រា ៨.-**

គ្រឿងសម្អាងដែលធ្វើអាជីវកម្មនៅលើទីផ្សារ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវផលិតក្នុងសហគ្រាស ដែលបានអនុវត្តតាមគោលការណ៍អនុវត្តផលិតកម្មល្អ ក្នុងការផលិតគ្រឿងសម្អាង ឬ គោលការណ៍អនុវត្តផលិតកម្មល្អអប្បបរមា ក្នុងការផលិតគ្រឿងសម្អាង ដែលទទួលយកបាន ដោយស្ថាប័នមានសមត្ថកិច្ច គ្រប់គ្រងគ្រឿងសម្អាង ។

**មាត្រា ៩.-**

ផលិតផលគ្រឿងសម្អាង ដែលធ្វើអាជីវកម្មលើទីផ្សារ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមបណ្តាលក្ខខណ្ឌ ដូចខាងក្រោម ÷

-ត្រូវមានគុណភាពនិងសុវត្ថិភាព ដោយមិនបង្កគ្រោះថ្នាក់ ដល់អ្នកប្រើប្រាស់

-ត្រូវមានស្លាកសញ្ញា ព្រឹត្តិបត្រព័ត៌មានណែនាំអំពីរបៀបប្រើ ការរក្សាទុក និង ការប្រុងប្រយ័ត្នក្នុងការប្រើ ។

**មាត្រា ១០.-**

ក្រសួងសុខាភិបាល ត្រូវចេញសេចក្តីព្រមាន ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលផលិត នាំចូល ចែកចាយ និងលក់ផលិតផលគ្រឿងសម្អាងខុសនឹងលក្ខខណ្ឌទាំងឡាយ ដែលនឹងត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

ក្នុងករណីគ្រឿងសម្អាងខាងលើ បានបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ រូបវន្តបុគ្គល ឬ នីតិបុគ្គលនោះ ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ជាធរមាន ។

## ជំពូកទី ៤
## បញ្ជីសារធាតុគ្រឿងសម្អាង

**មាត្រា ១១.-**

បញ្ជីសារធាតុផ្សំ ព្រមទាំងកម្រិតកំណត់របស់សារធាតុនីមួយៗ ដែលអនុញ្ញាតឱ្យប្រើក្នុងផលិតកម្មគ្រឿងសម្អាង និងបញ្ជីសារធាតុហាមឃាត់ ក្នុងផលិតកម្មគ្រឿងសម្អាង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៥
## ស្លាកសញ្ញាគ្រឿងសម្អាង

**មាត្រា ១២.-**

រាល់ផលិតផលគ្រឿងសម្អាងដែលបានអនុញ្ញាតឱ្យធ្វើអាជីវកម្ម ត្រូវតែមានស្លាកសញ្ញាស្របតាមបែបបទ ដែលនឹងកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៦
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ១៣.-**

ផលិតផលគ្រឿងសម្អាងគ្រប់ប្រភេទ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងសុខាភិបាល។ ក្រសួងសុខាភិបាលត្រូវរៀបចំ ÷

-បែបបទប្រវេទន៍គ្រឿងសម្អាង

-បែបបទ និងលក្ខខណ្ឌក្នុងការសុំបើក-បិទគ្រឹះស្ថានអាហ៍រំណែនីហរំណែគ្រឿងសម្អាង

-បែបបទ និងលក្ខខណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងសម្អាង

-ចំណាត់ប្រភេទគ្រឿងសម្អាងដែលមានចែងក្នុងបញ្ជីចំណាត់ប្រភេទចុងក្រោយ នៃសហគមន៍អាស៊ាន។

ចំណាត់ប្រភេទគ្រឿងសម្អាង ក្រៅពីបញ្ជីចំណាត់ប្រភេទចុងក្រោយ នៃសហគមន៍អាស៊ាន ត្រូវកំណត់ដោយប្រកាសរួម រវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ១៤.-**

ការណែនាំ និងការត្រួតពិនិត្យ ដែលពាក់ពន្ធ័នឹងផលិតផលគ្រឿងសម្អាង ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។ ក្រសួងសុខាភិបាល ត្រូវចាត់បញ្ជូនក្រុមត្រួតពិនិត្យ ព្រមទាំងភ្នាក់ងារ

សុខាភិបាល ដែលជាមន្ត្រីនគរបាលយុត្តិធម៌ ឱ្យចុះត្រួតពិនិត្យនៅតាមគ្រឹះស្ថាន ដែលធ្វើអាជីវកម្មគ្រឿងសម្អាង គ្រឹះស្ថានអាហារីណទីហារីណគ្រឿងសម្អាង ដើម្បី ÷

-ត្រួតពិនិត្យឯកសារបច្ចេកទេសគ្រឿងសម្អាង

-ស្រង់យកគ្រឿងសម្អាងគំរូ សម្រាប់ធ្វើការវិភាគគុណភាពក្នុងករណីចាំបាច់ រាប់ទាំងផលិតផលគ្រឿងសម្អាងដែលផលិតក្នុងស្រុក

-ឃាត់ទុកបណ្តោះអាសន្នវត្ថុតាង ដែលពាក់ព័ន្ធនឹងបទល្មើសជាក់ស្តែង និងរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ១៥.-**

ការប្រើប្រាស់ពាណិជ្ជនាម រូបភាពដែលប៉ះពាល់ដល់វប្បធម៌ជាតិ ឬអត្ថបទ របនាបថក្នុងគោលបំណងបំផ្លើស អំពីគុណភាពគ្រឿងសម្អាងតាមរយៈការផ្សព្វផ្សាយពាណិជ្ជកម្ម ត្រូវហាមឃាត់។

**មាត្រា ១៦.-**

ក្រសួងសុខាភិបាលមានសិទ្ធិផ្អាក ឬបញ្ឈប់ទាំងស្រុងការចរាចរ ការចែកចាយ និងការធ្វើអាជីវកម្មផលិតផលគ្រឿងសម្អាង ក្នុងករណីដែលពិនិត្យឃើញថា គ្រឿងសម្អាងនោះធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ ទោះបីគ្រឿងសម្អាងនោះ បានឆ្លើយតបទៅនឹងបណ្តាលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងអនុក្រឹត្យនេះក៏ដោយ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ១៧.-**

គ្រឿងសម្អាងទាំងឡាយណាដែលកំពុងចរាចរ និងកំពុងធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុញ្ញាតឱ្យបន្តធ្វើចរាចរ និងធ្វើអាជីវកម្ម ក្នុងរយៈពេល ៣៦(សាមសិបប្រាំមួយ) ខែទៀត ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន ក្នុងករណីដែលក្រសួងសុខាភិបាលពិនិត្យឃើញថា គ្រឿងសម្អាងនោះ មិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ។

ចំពោះផលិតផលគ្រឿងសម្អាង ដែលផលិតក្រោយការចូលជាធរមាននៃអនុក្រឹត្យនេះ ត្រូវឆ្លើយតបទៅតាមបណ្តាលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងអនុក្រឹត្យនេះ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

អនុក្រឹត្យលេខ ៣៣អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ៥ ៧ ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ